**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៧៨៩/១៩ ក.អ.ជ

ថ្ងៃ សុក្រ ១២ រោច ខែ អស្សុជ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩

# របាយការណ៍

## វឌ្ឍនភាពការងារប្រចាំខែកញ្ញា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### I. សេចក្តីផ្តើម

ក្នុងខែកញ្ញា ឆ្នាំ២០១៩ ទឹកជំនន់ទន្លេមេគង្គបានស្រកវិញបន្តិចនៅចុងខែកញ្ញានេះ ដោយបានបន្សល់ទុកនូវការខូចខាតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងសំណង់សិល្បការ្យមួយចំនួនធំ ដែលក្រសួងត្រូវដោះស្រាយបន្ទាន់ដើម្បីអាចឲ្យប្រជាពលរដ្ឋធ្វើដំណើរឡើងវិញបានបន្ទាប់ពីទឹកស្រកទៅវិញ ។ ថ្នាក់ដឹកនាំក្រសួងបានបន្តចុះរៀបចំវេទិកាសាធារណៈនៅតាមមូលដ្ឋានរៀងៗខ្លួនដើម្បីទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋយកមកដោះស្រាយទៅតាមផែនការដែលមាន និងបញ្ហាខ្លះត្រូវបានបញ្ចូលក្នុងផែនការឆ្នាំបន្ទាប់អាស្រ័យដោយលទ្ធភាពដែលក្រសួងអាចដោះស្រាយបាន។ ចំពោះការងារជំនាញ និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ការងារអាស៊ាន បានដំណើរការទៅដោយរលូន ។ ក្នុងខែកញ្ញានេះ ក្រសួងសម្រេចបានសមិទ្ធផលជាច្រើនដូចខាងក្រោម៖

### II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

#### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨០២ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែសីហា ឆ្នាំ២០១៩ គឺមានការកើនឡើងចំនួន ០១នាក់ ដោយការផ្ទេរក្របខណ្ឌចូល ។ ក្រសួងបានទទួលលិខិតចូលចំនួន ១៥៤ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៦៨ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ០២៣ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៥០ច្បាប់ ។

#### ២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែកញ្ញា ឆ្នាំ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិ សរុបចំនួន ២១ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០៧ ករណី ។

#### ៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែកញ្ញា នេះ ក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៣ ០៤០ ០៧២ ៤៦០ រៀល ស្មើនឹង ២,៣២% នៃច្បាប់ថវិកា



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

- ចំណាយមូលធនអនុវត្តបានចំនួន ១៦ ៤២៣ ៩២៤ ០០០ រៀល ស្មើនឹង ៨,៦៤% នៃច្បាប់ថវិកា ។

**៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- រៀបចំរបាយការណ៍សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤
- ត្រួតពិនិត្យ និងកែសម្រួលកម្មវិធីទាំង ៤ របស់ក្រសួងនៅលើឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ និងផែនការថវិកាឆ្នាំ២០២០ បន្ទាប់ពីចរចារថវិកា
- ដឹកនាំប្រតិភូចុះពិនិត្យសម្ភារៈ និងបណ្តាញព័ត៌មាន FMIS របស់ក្រសួងអភិវឌ្ឍន៍ជនបទជាមួយសវនករមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាគម្រោងមេគង្គឡាងឆាងស្តីពី Promoting Alliances on Rural Development and Poverty Eradication among LMC Countries នៅទីក្រុង Nay Pyi Taw ប្រទេសភូមា ដោយមានប្រទេសចូលរួមចំនួន ០៦ គឺ កម្ពុជា ចិន ភូមា ថៃ និង ឡាវ ប្រទេសវៀតណាម អវត្តមាន
- ចុះណែនាំការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តកំពត
- ចុះពិនិត្យការអនុវត្តផែនការឆ្នាំ ២០១៩ របស់មន្ទីរ នៅខេត្តរតនគិរី
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីការ ចូលរួមអ្នកប្រើប្រាស់ទិន្នន័យ សម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព SDGs នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាអន្តរក្រសួង ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ សម្រាប់ឆ្នាំ២០១៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- ផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលហ្សេឡង់
- ចូលរួមទស្សនកិច្ចសិក្សាស្តីពី ចលនាភូមិថ្មី នៅសាធារណៈរដ្ឋកូរ៉េ
- ចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការក្រៅរដ្ឋាភិបាលនៅខេត្តរតនគិរី និងស្ទឹងត្រែង ។

**៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាសទី៣ របស់ក្រសួងដឹកនាំដោយ **ឯកឧត្តម ហួត សារីម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តកែសម្រួលរៀបចំផែនការថវិកាកម្មវិធីឆ្នាំ២០២០ បន្ទាប់ពីការចរចារថវិកាលើកទី២
- ចូលរួមប្រជុំប្រកាសដាក់ឲ្យអនុវត្តជំនួយបច្ចេកទេសសម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រនៃកែទម្រង់ថវិកាឆ្នាំ២០១៨-២០២៥ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ដែលរៀបចំដោយក្រុមការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចូលរួមកិច្ចប្រជុំពិភាក្សាលើ ផែនការសកម្មភាព (MAP3) និងសូចនាករគន្លឹះ (KPI) ឆ្នាំ២០២០ របស់ក្រសួង-ស្ថាប័ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ នៅទីស្តីការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំសិក្ខាសាលាស្តីពីការសិក្សាស្វែងរកតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីអង្គភាពថវិកាថ្នាក់ខេត្ត ដើម្បីរៀបចំផែនការកសាងសមត្ថភាពដោយមានអ្នកចូលរួម ៥៨នាក់ ស្រី ១៦នាក់
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០២ គឺ ខេត្តព្រះវិហារ និងបន្ទាយមានជ័យ ។

៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២ រួមមាន ខេត្តបន្ទាយមានជ័យ និងពោធិ៍សាត់
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីអនាម័យក្នុងបរិស្ថានប្រឈមសម្រាប់គ្រួសារនៅជនបទ នៅសណ្ឋាគារ Great Duke រាជធានីភ្នំពេញ។

## III. សកម្មភាពការងារជំនាញ

១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងស្ថាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន ៩៦ គម្រោង កំពុងដំណើរការការដ្ឋានបានចំនួន ៧៦ គម្រោង លទ្ធផលគិតជាមធ្យម ៥៥.៤៨ %
- ការងារថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៩ មាន ចំនួន ២៨ គម្រោង ស្មើនឹង ៦៣ ខ្សែ ដំណើរការការដ្ឋានលទ្ធ ផលគិតជាមធ្យម ៧៩.៨៩ %
- ការងារថែទាំផ្លូវលក្ខណៈប្រចាំ ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៧២.២៧ %
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព ១០ គម្រោង អនុវត្តដោយ នាយកដ្ឋានស្ថាបនា និងវិស្វកម្មនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចរចាថ្លៃបានចំនួន ១៩គម្រោង អនុវត្តដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី ការងារនីតិកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ឈឹម សៅគី** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារនីតិកម្ម នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមសន្និសីទ លើកទី៣៧ (CAFEO-37) នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ាន ស្តីពី

"ពន្លឺបង្ហាញផ្លូវសម្រាប់ការដឹកនាំការអភិវឌ្ឍន៍ ប្រកបដោយចីរភាព" នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ។

២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ចុះត្រួតពិនិត្យ និងវាយតម្លៃគ្រឿងចក្រខួងអណ្តូងឯកជន នៅខេត្តកំពង់ធំ និងសៀមរាប
- ចុះសិក្សាទីតាំងដើម្បីរៀបចំប្រព័ន្ធខ្សែភ្លើង និងប្រព័ន្ធទុយោទឹកក្រោម នៅខេត្តកណ្តាល
- ចុះត្រួតពិនិត្យប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍ និងការស្តាប្រឡាយ នៅខេត្តរតនគិរី និងខេត្តព្រៃវែង
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំកម្មវិធីសម្រាប់ពង្រីកវិស័យទឹកស្អាត និងអនាម័យខេត្តកំពង់ឆ្នាំង ២០២០-២០២២ នៅខេត្តកំពង់ឆ្នាំង
- ចុះត្រួតពិនិត្យ សំណង់ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍ ខេត្តរតនគិរី
- ចូលរួមកិច្ចប្រជុំបច្ចេកទេស ស្តីពីការបង្កើតអនុសាសន៍សម្រាប់ផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងទីជម្រាល នៅរាជធានីភ្នំពេញ
- ចូលរួមកិច្ចប្រជុំ ពិភាក្សាការងារជាមួយ **លោក អ៊ាន វ៉ូសែល** ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី មេង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់បទសម្ភាសន៍ ស្តីពីការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជនបទ ជាមួយតំណាងអង្គការអាក់ស្យុងអេដ នៅនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ។

៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- ផ្តល់ចានបង្គន់តាមផ្ទះឯកជន បានចំនួន ៥៣ ចានបង្គន់ នៅខេត្តកែប
- រៀបចំកិច្ចប្រជុំបូកសរុបការងារចុះទស្សនកិច្ចសិក្សាអំពី អនាម័យនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី មេង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះរៀបចំយុទ្ធនាការផ្សព្វផ្សាយអនាម័យ នៅតាមខេត្តគោលដៅចំនួន១២ រួមមាន ខេត្តត្បូងឃ្មុំ កំពង់ចាម កោះកុង ប៉ៃលិន ស្វាយរៀង កែប សៀមរាប ក្រចេះ ព្រះសីហនុ កំពង់ស្ពឺ ឧត្តរមានជ័យ និងកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុបចំនួន ៩៣៧៩នាក់ ស្ត្រី ៦៨៩៩នាក់
- ដឹកនាំកិច្ចប្រជុំអនុក្រុមការងារលើកកម្ពស់អនាម័យ ( RUSH sub groups meeting ) ដើម្បីពិនិត្យមើលពីវឌ្ឍនភាពការងារជាមួយដៃគូអង្គការនានា ដោះស្រាយបញ្ហាប្រឈម និងចែករំលែកព័ត៌មានគ្នាទៅវិញទៅមក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF ក្នុងឃុំចំនួន ០៤ ក្នុងខេត្តសៀមរាប ដែលគាំទ្រដោយអង្គការ SNV ជាលទ្ធផលក្រុមការងារបានផ្តល់វគ្គតម្រង់ទិសដល់ក្រុមដើម្បីធ្វើការផ្ទៀងផ្ទាត់ទាំង ០៤ បានជាប់ជាភូមិ ODF ទាំងអស់
- រៀបចំឯកសារមេរៀន និងបង្រៀនអំពីការផ្ទេរមុខងារថ្នាក់ក្រោមជាតិ អំពីការលើកម្ពស់អនាម័យនៅជនបទទៅដល់ក្រុមការងារថ្នាក់ស្រុក ថ្នាក់ឃុំ ក្នុងខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់អនាម័យជនបទដល់ថ្នាក់ក្រោមជាតិនៅខេត្ត

ចំនួន ០២ រួមមានខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង ក្រោមអធិបតីភាព **ឯកឧត្តម គួច សោភា** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានអ្នកចូលរួមសរុប ចំនួន៨៧នាក់ ស្រី២២នាក់

- ចូលរួមវេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៧០ នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីលទ្ធផលនៃការវាយតម្លៃកម្មវិធីអភិវឌ្ឍន៍កុមារតូចចម្រុះវិស័យ ២០១៦-២០១៨ ដែលរៀបចំឡើងដោយ គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច (គ.ជ.គ.ក.) នៃក្រសួងអប់រំយុវជន និងកីឡា ។

## ៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការយុទ្ធសាស្ត្រស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ៥ ឆ្នាំលើកទី១ (២០១៩-២០២៣) នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ពិនិត្យ និងជួយរៀបចំឯកសារទូទាត់វគ្គបណ្តុះបណ្តាល ស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ចូលរួមសិក្ខាសិលាចែករំលែកបទពិសោធន៍
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ចលនាភូមិថ្មី នៅសាធារៈរដ្ឋកូរ៉េ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងវគ្គទី២ ឆមាសទី២ ឆ្នាំ២០១៩ ចំនួន ០៤ មុខជំនាញ មានសិក្ខាកាមចំនួន ១១៩ នាក់ ស្រី ៥៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌល ចំនួន១៧វគ្គ មានសិក្ខាកាមចំនួន ៣៦០នាក់ ។

## ៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១៨៥នាក់ ក្នុងនោះស្រីចំនួន ១៨នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៧៥នាក់ ក្នុងនោះស្រីចំនួន ១៣នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ១០នាក់ ក្នុងនោះស្រីចំនួន ០៦នាក់
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល និងចូលរួមសិក្ខាសាលាក្នុងប្រទេស និងក្រៅប្រទេស ជូនមន្ត្រី ចំនួន ០៣នាក់
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមកម្មវិធីអាហារូបករណ៍ (JDS) របស់រាជរដ្ឋាភិបាលជប៉ុន សម្រាប់ឆ្នាំសិក្សា ២០១៩ សិក្សានៅប្រទេសជប៉ុន
- បានរៀបចំឯកសារឆ្លើយតបលើការជ្រើសរើសវគ្គបណ្តុះបណ្តាលចំនួន ០៤វគ្គ នៃកម្មវិធីវគ្គបណ្តុះបណ្តាលរយៈពេលវែង របស់រាជរដ្ឋាភិបាលជប៉ុន ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានជួបសំណេះសំណាលជាមួយប្រតិភូយុវជនកម្ពុជា សម្រាប់កម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា និងជប៉ុន (SSEAYP) លើកទី៤៦ ឆ្នាំ២០១៩ ក្រោមអធិបតីភាព

**ឯកឧត្តម ឈឹម សៅគី** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- រៀបចំឯកសារចាត់បញ្ជូនមន្ត្រីចំនួន ០២រូប ដើម្បីចូលរួមជាភ្ញៀវកិត្តិយសក្នុងសមាជលំដាប់ថ្នាក់អន្តរជាតិលើកទី៣ ស្តីពី "Building and Harmonizing Digital Workforce" ដែលនឹងប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន រាជធានីភ្នំពេញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង សម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥០នាក់ ស្រី ៦៦នាក់ លើ ០៧មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ បានបន្តដំណើរការបណ្តុះបណ្តាល សម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៦០នាក់ ស្រី ១០០នាក់ លើ ០៥មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបើកវគ្គបណ្តុះបណ្តាលរយៈពេលវែង សម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧០នាក់ ស្រី ៣៦នាក់ លើ ០៤មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង សម្រាប់ឆមាសទី ២ និងបើកវគ្គរយៈពេលខ្លី ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥០ នាក់ ស្រី ១០៩នាក់ លើ ០៤មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង និងបានបើកវគ្គរយៈពេលខ្លី សម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៩នាក់ ស្រី៤០ នាក់ លើ ០៣មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានបើកវគ្គរយៈពេលខ្លី សម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៣៣នាក់ ស្រី ២៦នាក់ លើមុខវិជ្ជាបច្ចេកទេសចិញ្ចឹម និងព្យាបាលមាន់លក្ខណៈគ្រួសារ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបញ្ចប់វគ្គបណ្តុះបណ្តាល លើមុខវិជ្ជាភាសាអង់គ្លេស សម្រាប់ឆមាសទី ១ និងសម្រាប់ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤១នាក់ ស្រី ១៨នាក់ និងបន្តការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលការថែទាំ និងជួសជុលអណ្តូងស្នប់ ដល់ប្រជាពលរដ្ឋក្នុងស្រុកភ្នំស្រុក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សម្រាប់ ឆមាសទី ២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤០នាក់ ស្រី ១៧នាក់ លើ ០២មុខជំនាញ ។

៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ប្រតិបត្តិការឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១៤៤ ៣១៥ ៥៣៥

រៀល (បួនពាន់មួយរយសែសិបបួនលានបីរយដប់ប្រាំពាន់ប្រាំរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៥៥ ៣០៤,៨៤ ដុល្លារអាមេរិក (មួយលានហាសិបប្រាំពាន់បីរយបួនដុល្លារនិងប៉ែតសិបបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៣១៩ នាក់ នៅភូមិគោលដៅចំនួន ២២៣ ភូមិ ១០០ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥

- ធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែក បច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦នាក់ ស្រី ៦៤នាក់ នៅខេត្តស្វាយរៀង
- ចុះតាមដានសកម្មភាពសិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាលគំនិតផ្តួចផ្តើមបង្កើតអាជីវកម្មខ្នាតតូច និងបច្ចេកទេសផលិតសាប៊ូលាងចាន នៅខេត្តសៀមរាប តាកែវ និងកំពង់ធំ
- ចុះសិក្សាពីស្ថានភាពផ្សារជនបទ ដើម្បីរកលទ្ធភាពធ្វើការកែលម្អ នៅខេត្តកំពង់ឆ្នាំង
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិស្តីពី យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៩-២០២៣ ដល់អន្តរក្រសួង និងដៃគូអភិវឌ្ឍន៍នានា ក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅសណ្ឋាគារបុរីអង្គរ ខេត្តសៀមរាប ។

## ៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- រៀបចំប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិចលើកទី២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅក្រុងបានលុង ខេត្តរតនគិរី
- បានប្រជុំពិភាក្សាការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិចជាមួយអង្គការដៃគូ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥
- ចូលរួមជាអធិបតី និងវាគ្មិនក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី ការពិនិត្យឡើងវិញលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងលទ្ធភាពនៃការចុះបញ្ជីដីសមូហភាពជនជាតិដើមភាគតិចនៅខេត្តរតនគិរី ដែលប្រព្រឹត្តទៅនៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាស្តីពី "Good Governance of Ethnic Issues Among Lancang Mekong Cooperation Member state in 2019" នៅទីក្រុងប៉េកាំង ប្រទេសចិន ។

## ៨. ការងារយេនឌ័រ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិភាក្សាជាមូលដ្ឋាន លើយន្តការសម្របសម្រួលកិច្ចការពារកុមារ ដែលមានស្រាប់នៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ

នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- រៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ
- រៀបចំកិច្ចប្រជុំដំបូងរបស់ក្រុមលេខាធិការដ្ឋានវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីរៀបចំផែនការបណ្តុះបណ្តាលមុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ និងជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ប្រជុំពិភាក្សាជាមួយនាយកដ្ឋានជំនាញ ដើម្បីរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ២០២០ សម្រាប់រៀបចំការបណ្តុះបណ្តាលមុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ និងមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ចូលរួមក្នុងព្រឹត្តិការណ៍រៀនសូត្រថ្នាក់ជាតិ ស្តីពីការគាំទ្រជំនួយបច្ចេកទេសសម្រាប់គម្រោងផ្តល់សេវាអនាម័យជនបទតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ នៅសណ្ឋាគារសាន់វ៉េ
- ចូលរួមក្នុងវេទិកាស្តីពីនីតិកម្ម និងការកែទម្រង់របស់រាជរដ្ឋាភិបាលនៅ សណ្ឋាគារសុខាភ្នំពេញ ។

## IV. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ

### ១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ខែកញ្ញានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៥៧,៩១%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៦៥,៤៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៥០,៣៦%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៦០,០៣%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៤៨,២៩%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែង

សរុប ១២៥,៥០គ.ម សម្រេចបាន ១០០%

- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ ខែកញ្ញានេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ៤៨,៧២%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ៤៥% ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទដោយត្រូវអនុវត្តជា ២ដំហាន ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គិតត្រឹមខែកញ្ញានេះ គម្រោងដែលបានស្នើសុំក្រាលក្រួសក្រហមចំនួន ១៤១គម្រោង បានបញ្ចប់ការងារ បានចំនួន ១៣៩គម្រោង ប្រវែងសរុប ៥៤៥ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ដំហាន ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០គម្រោង ប្រវែង ១៦១ ៤០៦ ម៉ែត្រ ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សង់បង្គន់សាធារណៈ និងអាងត្រងទឹកភ្លៀងសាធារណៈបានចំនួន ១០ កន្លែង និងសាងសង់ថ្លុលហាលលាមក សម្រេចបាន ១០០% នៅខេត្តបន្ទាយមានជ័យ
- ដឹកសម្ភារបង្គន់គ្រួសារចែកជូនប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋបានធ្វើបង្គន់អនាម័យរួចរាល់បានចំនួន ១ ៩៥៨ ខ្នងផ្ទះ និងសាងសង់បង្គន់ ABC សម្រេចបាន ៥% នៅខេត្តបន្ទាយមានជ័យ ។

**៥. គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាង** (Mekong Lancang Cooperation = MLC )

គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាងដំហានទី២ សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទអនុវត្តលើកម្មវិធីចំនួន ២ គឺ៖ ទី១ គម្រោងកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច ជនបទ និងទី២ គម្រោងអភិវឌ្ឍន៍សហគមន៍ចម្រុះតាមដងទន្លេមេគង្គ ដែលជាជំនួយឥតសំណងរបស់សាធារណៈ

វេជ្ជប្រជាមានិតចិន ។ ក្នុងខែកញ្ញានេះ គម្រោងបានអនុវត្តន៍ ៖

- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប៉ះពាល់នៃសារជាតុគីមី បច្ចេកទេសដាំបន្លែតាមបែបធម្មជាតិ និង ការបង្កើតសួនដំណាំតាមផ្ទះ បានចំនួន ០៣វគ្គ ។

## V. សេចក្តីសន្និដ្ឋាន

យោងតាមសេចក្តីរាយការណ៍ខាងលើ បានបង្ហាញពីការចូលរួមយ៉ាងសកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDGs ក្នុងជំហានឆ្ពោះទៅជំរុញការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមតំបន់ជនបទ លើកម្មវិធី សាងសង់ ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ទឹកស្អាត អនាម័យ ការងារសហគមន៍ ពិសេសគឺបណ្តុះបណ្តាលជំនាញបច្ចេកទេសដើម្បីបង្កើតមុខរបរ និងសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទ ក្នុងគោលដៅបង្កើនប្រាក់ចំណូលក្នុងតាមគ្រួសារនីមួយៗដើម្បីឲ្យបានគុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជននៅជនបទនៃព្រះរាជាណាចក្រកម្ពុជា ដែលជាគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងនីតិកាលទី៦ នេះឲ្យទទួលបានជោគជ័យ ៕

**រដ្ឋមន្ត្រី**

បណ្ឌិត អ៊ុក រ៉ាប៊ុន